ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ — ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧៨៩/០១-១០-២០១០

សាលដីកា

លេខ: ៣០ ក្រv បស

ចុះថ្ងៃទី២០-០៥-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២០-០៥-២០១១ដែលមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៧៨៩ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] អន្លូមាស ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] មុខរបរ រកស៊ី ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ០៥-០៣-២០១០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនរបស់សាលាឧទ្ធរណ៍លេខ: ០៤ ដ.ក.ឧ/២០១០ ចុះថ្ងៃទី២៥-០២-២០១០ ។

-ដោយមានលោក [redacted] សុវណ្ណលី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ជាប់ចោទពីបទ: រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅស្រុកស្រែ អំបិល ខេត្តកោះកុង កាលពីថ្ងៃទី១៦-១១-២០០៨ ដល់ឆ្នាំ ២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥០ និងមាត្រា ៨៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានក្រុមហ៊ុន ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ។

-ដោយមានលោក [redacted] ទ្រី ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី .

## **ឯរឿងហេតុមានដូចតទៅ**

**សកម្មភាព** ប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី២០-០៦-២០០៨ ឈ្មោះ [redacted] ដួងជាកស៊ីវង្ស ជាតំណាងឲ្យក្រុមកោះកុង ស៊ុរហ្វ៉ីរ អ៊ីនដាស្ទ្រីខមភេនី លីមីតធីត (KSI) បានចុះកិច្ចសន្យាព្រមព្រៀមគ្នាជាមួយក្រុមហ៊ុន [redacted] ដែលឈ្មោះ [redacted] ទ្រី ជាប្រធាន និងឈ្មោះ [redacted] អន្លូមាស ជាតំណាង ដើម្បីម៉ៅការជីកដីជីកដី ពីអាងស្តុបទឹកធ្វើទំនប់ឲ្យក្រុមហ៊ុន KSI ដែលមានទីតាំងនៅភូមិកណ្តាល ឃុំជីខលី ស្រុកស្រែអំបិល ខេត្តកោះកុង បន្ទាប់ពីធ្វើកិច្ចសន្យារួចរាល់ហើយ ក្រុមហ៊ុន គុជ ទ្រី បានអនុវត្តចប់សព្វគ្រប់តាមការព្រមព្រៀងគ្នា រួចប្រគល់ទីតាំងនោះទៅឲ្យក្រុមហ៊ុន KSI តែនៅថ្ងៃទី១៦-១១-២០០៨ ឈ្មោះ [redacted] អន្លូមាស បានក្លែងលិខិតផ្ទេរសិទ្ធិ ដោយបន្លំជាតំណាងឲ្យឈ្មោះ [redacted] ទ្រី ហើយទៅបើកប្រាក់ពីក្រុមហ៊ុន KSI ចំនួន ៧៩.០៦២.៥០ $ (ប្រាំពីរម៉ឺនប្រាំមួយពាន់ហុកសិបពីរដុល្លា អាមេរិក និងហាសិបសេន) មិនបានប្រគល់ទៅឲ្យឈ្មោះ [redacted] ទ្រី ទេ ។ ក្រោយមកនៅខែមករា ឆ្នាំ២០០៩ ក្រុមហ៊ុន [redacted] បានទទួលម៉ៅការការប្រេកដំបូលរោងចក្រស្តុសឲ្យក្រុមហ៊ុន KSI ទៀត ក្នុងនោះ ឈ្មោះ កាំង អន្លូមាស ជាអ្នកទទួលកំរៃជើងសារឲ្យក្រុមហ៊ុន នៅពេលធ្វើដំបូលរួចហើយឈ្មោះ [redacted] ទ្រី ទៅបើកប្រាក់ដំណាក់កាលពីក្រុមហ៊ុន KSI ទើបដឹងថាឈ្មោះ [redacted] អន្លូមាស បានប្រាក់ពីក្រុមហ៊ុន KSI អស់ចំនួន ២២៨.៥៧៩.០០ ដុល្លា (ពីរសែនពីម៉ឺនប្រាំបីពាន់ប្រាំរយចិត សិបប្រាំបួនដុល្លាអាមេរិក ) ប្រគល់ឲ្យឈ្មោះ [redacted] ទ្រី ចំនួន ១០៦.៨៨៨.០០$ (មួយសែនប្រាំមួយពាន់បួនរយប៉ែតសិបប្រាំបីដុល្លាអាមេរិក ) ហើយក៏បកេងយកអស់ចំនួន ១២២,០៩១.០០ $ (មួយសែនពីរពាន់កៅសិបមួយដុល្លាអាមេរិក ) ។

**ឃ្មានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ៣០ "គ" ចុះថ្ងៃទី០២-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ឲ្យឈ្មោះ [redacted] អន្លូមាស ភេទស្រី អាយុ ២៥ឆ្នាំ រួចផុតពីបទ: ក្លែងលិខិតឯកជន ប្រព្រឹត្តនៅស្រុកស្រែ អំបិល ខេត្តកោះកុង កាលពីថ្ងៃទី១៦-១១-២០០៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អន្លូមាស ហៅ អាមួយ ភេទស្រី អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) ពីបទៈ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅស្រុកស្រែ អំបិល ខេត្តកោះកុង កាលពីឆ្នាំ ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] អន្លូមាស ហៅ អាមួយ សងសំណងទៅឲ្យឈ្មោះ [redacted] ទ្រី ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១២,០៩១.៥០ $ (មួយសែនមួយម៉ឺនពីរពាន់កៅសិបមួយដុល្លាអាមេរិក និងហាសិបសេន ) សំណូមពរលើសពីនេះត្រូវបដិសេធចោល



៣០០

Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០-៨-២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២-៩-២០១០ ចំពោះមុខជនជាប់ចោទ,មេធាវីការសិទ្ធិជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់ ។

**ឃ្មានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៦១៣ ចុះថ្ងៃទី០៩-៩-២០១០ របស់ជនជាប់ចោទ ឈ្មោះ [redacted] អន្តមាស ហៅ មួយ សុំប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខៈ ៣០ "ត" ចុះថ្ងៃទី០២-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល។

**ឃ្មានឃើញ** របាយការណ៍រឿង ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ ។

**ឃ្មានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## **នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted] អន្តមាស (វត្តមាន)

-មេធាវីការពារ [redacted] សុវណ្ណាលី (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទ្រី (វត្តមាន)

-មេធាវីៈ [redacted] ទ្រី (អវត្តមាន)

ស.ឆៈ [redacted] អន្តមាសៈ ខ្ញុំមិនសុខចិត្តព្រោះសំរេចសេចក្តីអោយខ្ញុំសងច្រើន ខុសពីការព្រមព្រៀងក្នុងកិច្ចសន្យាដែលបានព្រមព្រៀងគ្នាលើប្រាក់តែចំនួន៨៧៣០២ដុល្លាប៉ុណ្ណោះចំនួនលើសពីនេះខ្ញុំមិនទទួលស្គាល់ទេ ពេលនេះខ្ញុំសុំបន្ធូរបន្ថយទោស ។

ស.ឆៈ [redacted] ទ្រីៈ ចំពោះប្រាក់នៅជំពាក់មានចំនួន ១១២,០៩១.៥០ $ ចំនែកកិច្ចសន្យាដែលជនជាប់ចោទអះអាងនោះ មិនទទួលស្គាល់ទេ ។ សុំតំកលើសាលក្រមសាលាដំបូងទុកជាបានការដដែល និងបន្ថែមប្រាក់ជំងឺចិត្ត និងបន្ថែមទោស ។

ស.ឆៈ [redacted] អន្តមាសៈ ខ្ញុំបានធ្វើកិច្ចសន្យាសុំសងលុយ ៨៧៣០២ ដុល្លា ហើយសន្យា ១ខែ ចំនួន ១០០០០ ដុល្លាអាមេរិក ។

## **សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ**

សូមតម្កល់សាលក្រមព្រហ្មទណ្ឌទុកជាបានការ ។

មេធាវីៈ [redacted] សុវណ្ណាលី រឿងនេះជាវិវាទកិច្ចសន្យា កូនក្តីខ្ញុំទទួលស្គាល់ការជំពាក់ប្រាក់ព្រមសង ៨៧៣០២ ដុល្លា ជាដំណាក់កាល ហើយរឿងនេះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ សុំលើកលែង ការចោទដល់កូនក្តីខ្ញុំ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់រួចមក ។

**សាលាឧទ្ធរណ៍យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦១៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] អន្លូមាស ហៅមួយ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គុជ ទ្រី ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

៣-មានភស្តុតាងដែលបញ្ជាក់ពីពិរុទ្ធភាពលើឈ្មោះ [redacted] អន្លូមាស ហៅមួយ ពិតជាបានប្រព្រឹត្ត បទរំលោភលើសេចក្តីទុកចិត្ត ប្រាកដមែន ។ តាមការបញ្ជាក់របស់ជនជាប់ចោទនាពេលសវនាការ ថាខ្លួនមិនមានភាគហ៊ុនជាមួយឈ្មោះ [redacted] ទ្រី ទេ គ្រាន់តែធ្លាប់ទំនាក់ទំនងរកស៊ីជាមួយគ្នាពីមុន ។ ខ្លួនពិតជាបានទៅដកប្រាក់ពីក្រុមហ៊ុន KSI ជំនួសឈ្មោះ [redacted] ទ្រី ពិតមែន ប្រាក់ដែលដកបាន បានប្រគល់ឲ្យឈ្មោះ [redacted] ទ្រី ខ្លះ នៅសល់ខ្លះខ្លួនយកទៅរកស៊ី ។ ក្រោយពីមានបណ្តឹងរបស់ឈ្មោះ [redacted] ទ្រី ខ្លួនបានសំរួលជាមួយឈ្មោះ [redacted] ទ្រី ដើម្បីសុំសងប្រាក់គាត់ចំនួន ៨៧.៣០២ ដុល្លា តាមលិខិតចុះថ្ងៃទី០៩-៩-២០០៩ ។

៤-តាមការបញ្ជាក់របស់ដើមបណ្តឹងឈ្មោះ [redacted] ទ្រី ថាឈ្មោះ កាំងអន្លូមាស នេះមិនមានភាគហ៊ុនជាមួយក្រុមហ៊ុនខ្លួនទេ ហើយឈ្មោះ [redacted] អន្លូមាស បានយកឈ្មោះរបស់ខ្លួនជាប្រធានក្រុមហ៊ុន ដើម្បីបើកប្រាក់ក្រុមហ៊ុន ។ ប្រាក់ដែលឈ្មោះ [redacted] អន្លូមាស បើកមានចំនួន ២២៨.៥៧៩ ដុល្លា បានប្រគល់ឲ្យខ្លួនមួយចំនួន ហើយនៅប្រាក់ចំនួន ១១២.០៩១,៥០ ដុល្លា មិនបានប្រគល់ឲ្យ ។ ក្រោយពីមានពាក្យបណ្តឹងឈ្មោះ [redacted] អន្លូមាស បានសុំសំរួលមកសុំសងខ្លួនចំនួន ៨៧.៣០២ ដុល្លា តាមលិខិតចុះថ្ងៃទី ០៩-៩-២០០៩ តែខ្លួនមិនព្រមទទួលយក ។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អន្លូមាស ដែលបានទៅដកប្រាក់របស់ឈ្មោះ [redacted] ទ្រី ពីក្រុមហ៊ុន KSI ជំនួសឈ្មោះ [redacted] ទ្រី ដោយខ្លួនគ្មានសិទ្ធិទេនោះ គឺជាអំពើ រំលោភលើសេចក្តីទុកចិត្ត ។

៦-ដើមបណ្តឹងបានសុំឲ្យសាលាឧទ្ធរណ៍បន្ថែមប្រាក់សំណងជំងឺចិត្តបន្ថែមទៀត ព្រោះខ្លួនមានការខាតបង់ច្រើនដោយសារតែអំពើរបស់ជនជាប់ចោទ តុលាការយល់ឃើញថា ការសំរេចឲ្យបង់ប្រាក់ជំងឺចិត្តរបស់សាលាដំបូងមានលក្ខណៈសមស្របហើយ សាលាឧទ្ធរណ៍មិនផ្តល់ប្រាក់ជំងឺចិត្តបន្ថែមទៀតទេ ។

៧-តុលាការសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ បញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ មិនចាំបាច់សរសេរបញ្ជាក់សារជាថ្មីនោះទេ ។ សេចក្តីសំរេចនៃសាលក្រមលេខ ៣០ "គ" ចុះថ្ងៃទី០២-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតំកល់ទុកជាបានការ ។



៣០២

Scanned with CamScanner

## ហេតុដូច្នេះទើបសម្រេច

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦១៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ របស់ជនជាប់ចោទ ឈ្មោះ [redacted] អន្លមាស ហៅ មួយ ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធដោយទាស់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ទ្រី ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធដោយទាស់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមលេខ ៣០ "គ" ចុះថ្ងៃទី០២-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៤-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] អន្លមាស ហៅ មួយ តាមនីតិវិធីច្បាប់ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ ដោយសំរេចសេចក្តី:

-ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អន្លមាស

- ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទ្រី

-បើកសិទ្ធិប្តឹងសារទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចនគ្របើជាន់ថ្នាក់ គ្រប់តំណែងនិងកងកំលាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី 12 ខែ 7 ឆ្នាំ២០១១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]



៣០៣